គណៈកម្មាធិការព្រំដែនកម្ពុជា
សមាគម មិនជាប់ពាក់ព័ន្ធ នឹង គណៈបក្ស នយោបាយ
 គ.ព.ក CFC-CBC
Comité des Frontières du Cambodge ( C F C )
Cambodia's Border Committee ( C B C )
ASSOCIATION NON APPARENTEE AU PARTI POLITIQUE ASSOCIATION UNAFFILIATED TO A POLITICAL PARTY

# សេចក្តីថ្លែងការណ៍
## អំពី ការផ្ទេរ មាត្រដ្ឋាន នៃផែនទីភូមិសាស្រ្ត នៃប្រទេសកម្ពុជា

លោកនាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន ក្រោយជំនួប កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ជាមួយនាយករដ្ឋមន្ត្រីវៀតណាម លោក ង្វៀង ស៊ន់ ភៀក (Nguyen Xuan Phuc) នៅខេត្តសៀមរាប (កម្ពុជា) នោះ បានថ្លែងថា គូរភាគីទាំងពីរ បានសំរេចសុំជំនួយ ពីប្រទេសបារាំង ដើម្បីធ្វើការផ្ទេរ មាត្រដ្ឋាន នៃផែនទីភូមិសាស្រ្ត នៃប្រទេសកម្ពុជា ពីខ្នាត១/១០០០០០ នៃប្រព័ន្ធ"បោន" (BONNE) ទៅជាផែនទីខ្នាត១/៥០០០០ នៃប្រព័ន្ធ"យូធីអឹម"(UTM)វិញ ដើម្បី"ដោះស្រាយនូវចំណុចវិវាទខ្លះៗ នៃព្រំដែនរវាងប្រទេសទាំងពីរ"។

ក្នុងរឿងជម្លោះដ៏យូរអង្វែង រវាងប្រទេសទាំងពីរ អំពីការកំណត់ព្រំដែនជាថ្មី សេចក្តីសំរេចចុងក្រោយនេះ ក៏បានចោទជាសេចក្តីសង្កេត និងសំនួរជាច្រើនថែមទៀត ដូចតទៅ។

ការផ្ទេរប្រព័ន្ធ និងមាត្រដ្ឋាន ពីមួយទៅមួយថ្មីទៀត នៃផែនទីភូមិសាស្រ្ត គឺជា វិធីបច្ចេកទេសបន្ទាប់បន្សំមួយ ដែលគេអាចធ្វើបាន នៅគ្រប់ពេលវេលាទាំងអស់ ដោយមានភាពលំអៀងខ្លះៗ ដែលគេអាចកែតម្រូវបាន ជាបន្ទាប់មកទៀត។ ប៉ុន្តែសំនួរសំខាន់បំផុត ដែលគេចង់ដឹង ចំពោះករណីរបស់ខ្មែរយើង គឺថា តើផែនទីមួយណានៃប្រទេសកម្ពុជា ដែលគេនឹងដាក់ ឲ្យធ្វើការកែប្រែ ដែលគេបានគ្រោងធ្វើនោះ?។

យើងសូមរំឭកថា ប្រទេសបារាំង ដែលជាអតីតមហាអំណាចអាណានិគម នៃឥណ្ឌូចិន បន្ទាប់ពីមាន អនុសញ្ញា កិច្ចព្រមព្រៀង និងអត្ថបទគតិយុត្តផ្សេងៗ បានតាក់តែង និងដាក់ឲ្យអនុមតិ នៅក្នុងអំឡុងពាក់កណ្តាលដើម នៃសតវត្សទី២០ នូវព្រំដែនរដ្ឋ នៃប្រទេសកម្ពុជា ប្រទេសវៀតណាម និងប្រទេសលាវ ផងដែរ ដោយផែនទីភូមិសាស្រ្ត តាមខ្នាត១/១០០០០០ នៃប្រព័ន្ធបញ្ចាំងនិយាមការ "បោន"តែមួយ ដូចគ្នាទាំងអស់។ ម្យ៉ាងទៀត ផែនទីទាំងនោះ ក៏ត្រូវបានទទួលស្គាល់ជាផ្លូវការ ពីសន្និសិទក្រុងហ្សឺណែវ ស្តីពីឥណ្ឌូចិន កាលពីខែកក្កដា ឆ្នាំ១៩៥៤ រួចហើយដែរ។ ជាបន្ទាប់មក នៅឆ្នាំ១៩៦៧ រដ្ឋាភិបាលក្រុងហាណូយ (សាធារណរដ្ឋ ប្រជាធិបតេយ្យ វៀតណាម ឬ "វៀតណាមខាងជើង" និង "រណសិរ្សជាតិ រំដោះវៀតណាមខាងត្បូង" ក៏បានបញ្ជាក់ជាឧឡារឹក និងជាលាយលក្ខអក្សរ ថ្វាយចំពោះសម្តេចនរោត្តម សីហនុ ជាប្រមុខរដ្ឋកម្ពុជា នូវ"ការគោរពយ៉ាងដាច់ខាត"របស់ខ្លួន ចំពោះបូរណភាពដែនដី នៃប្រទេសកម្ពុជា "នៅក្នុងព្រំដែនបច្ចុប្បន្ន" គឺថា ព្រំដែន នៃខែកក្កដា ឆ្នាំ១៩៥៤ នៃផែនទី តាមប្រព័ន្ធ"បោន" ខ្នាត១/១០០០០០ នៃប្រទេសកម្ពុជានោះឯង។ តាមលក្ខណៈប្រក្រតី គឺថា

គ្រប់ដំណោះស្រាយវិវាទ អំពីព្រំដែនវៀតណាមនិងកម្ពុជា ត្រូវតែផ្អែកលើមូលដ្ឋាន និងផ្អែកទាំងស្រុង ជាដាច់ខាត លើផែនទីប្រព័ន្ធ"បោន" ខ្នាត១/១០០០០០នេះ ដែលប្រទេសបារាំងអាណានិគម បាន បន្សល់ទុកមកឲ្យ ជាប្រវត្តិសាស្ត្រ សំរាប់ប្រទេសទាំងពីរនេះ រៀងខ្លួនហើយ។

គេត្រូវរំឭកផងដែរថា ព្រំដែនដីគោក រវាងកម្ពុជានិងវៀតណាម - គឺ"កូសាំងស៊ីនបារាំង" នាសម័យនោះ ត្រូវបានកំណត់ជាក់ស្តែង តាមរយៈការបោះបង្គោលចំនួន១២៤ នាដើមសតវត្សទី២០ ដោយអនុវត្តតាមអនុសញ្ញា បារាំង-ខ្មែរ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៨៧៣។ ព្រំដែននេះសោត (តាមឯកសារ របស់លោកសារិន ឆាក) ត្រូវបានកំណត់ ដោយគេបានឲ្យប្រៀបជាច្រើនណាស់ទៅហើយ ដល់កូសាំងស៊ីន លើប្រទេសកម្ពុជា និងការបោះបង្គោល បានធ្វើដោយអាជ្ញាធរបារាំង ជាមួយនឹងសហការី របស់គេ ដែលជាជនជាតិអាណ្ណាម (យួន)ទាំងអស់។

ក៏ប៉ុន្តែ នៅឆ្នាំ១៩៧៨ សាធារណរដ្ឋ សង្គមនិយម វៀតណាម (សសវ) បានឈ្លានពាន លើប្រទេសកម្ពុជា ហើយនៅក្នុងអំឡុងពេល ខ្លួនកាន់កាប់ និងត្រួតត្រាប្រទេសនេះ (១៩៧៩-១៩៩១) ក៏បានផ្តើមកែប្រែ ក្នុងផលប្រយោជន៍ដ៏ធំរបស់ខ្លួន នូវព្រំដែនរវាងប្រទេសទាំង២ ដោយមានការយល់ព្រម ពីរបស់ហៅថា"សាធារណរដ្ឋ ប្រជាមានិត កម្ពុជា (សបក)" នៃលោកហ៊ុន សែន ដែលវៀតណាម បានលើកបន្តុប នៅក្រុងភ្នំពេញនោះ ជាពិសេសតាមរយៈ "កិច្ចព្រមព្រៀង កំណត់ព្រំដែនរដ្ឋ" ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៨៥។ ក្រៅពីលក្ខណៈមិនស្របច្បាប់ (និងមិនស្មើភាពគ្នា) សន្ធិសញ្ញានេះ បានយោងទៅលើផែនទីភូមិសាស្ត្រ ពីរបែប ផ្សេងៗពីគ្នា គឺ : មាន៤០ផ្ទាំងជាផែនទី "បោន" (BONNE) ខ្នាត១/១០០០០០ និងមាន២៦ផ្ទាំងជាផែនទី"យូធីអឹម"(UTM) ខ្នាត១/៥០០០០ផង។ ប្រទេសកម្ពុជាពុំដែលបានទទួលស្គាល់ ផែនទី"យូធីអឹម"នេះឡើយ ពីព្រោះវាត្រូវបានគាក់តែងឡើង ដោយកងយោធាអាមេរិក ក្នុងទសវត្ស១៩៦០ ដើម្បីសេចក្តីត្រូវការរបស់គេ ក្នុងសង្គ្រាមវៀតណាម ដោយយកទិន្នន័យដែនដី របស់រដ្ឋាភិបាលក្រុងសៃហ្គុង (សាធារណរដ្ឋវៀតណាម ឬ "វៀតណាមខាងត្បូង") នាសម័យនោះ ដែលបានវាតទីជាច្រើនចំណែក លើដែនដី នៃកម្ពុជា។

នៅខែតុលា ឆ្នាំ១៩៩១ កិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស៍ ស្តីពីកម្ពុជា ដែលវៀតណាម និងភាគីលោកហ៊ុន សែន ជាហត្ថលេខីផងដែរនោះ បានដាក់បញ្ញត្តិយ៉ាងជាក់ច្បាស់ ឲ្យអ្នកទាំងនេះ "លុប" សន្ធិសញ្ញារបស់ពួកគេ ដែលប៉ះពាល់ ដល់បូរណភាពដែនដី នៃប្រទេសកម្ពុជា។ រដ្ឋធម្មនុញ្ញខ្មែរ នៃថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ក៏បានបញ្ជាក់ជាបន្ថមកទៀត នៅក្នុងមាត្រា២ ដោយបានចែងថា: "បូរណភាពទឹកដី របស់ព្រះរាជាណាច្រកម្ពុជា ពុំអាចរំលោភបានដាច់ខាត ក្នុងព្រំដែនរបស់ខ្លួន ដែលមានកំណត់ ក្នុងផែនទី ខ្នាត១/១០០០០០ ធ្វើនៅចន្លោះឆ្នាំ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ នៅចន្លោះឆ្នាំ១៩៦៣-១៩៦៩"។ មាត្រា៥៥ នៃរដ្ឋធម្មនុញ្ញ ក៏បានចែងបន្ថែមទៀតថា:"សន្ធិសញ្ញានិងកិច្ចព្រមព្រៀង ទាំងឡាយណា ដែលមិនស្របនិង ឯករាជ្យ អធិបតេយ្យ បូរណភាព ទឹកដី អព្យាក្រិតភាព និងឯកភាពជាតិ របស់ព្រះរាជាណាចក្រកម្ពុជា ត្រូវលុបចោល"។

ថ្វីត្បិតតែជាយ៉ាងនេះក្តី ក៏សន្ធិសញ្ញាយួនឆ្នាំ១៩៨៥ខាងលើនេះ នៅតែគេបន្តអនុវត្តនៅលើដែនដីផ្ទាល់ រួចជាបន្ទាប់មក ត្រូវគេបំពេញបន្ថែម នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៥ "ដោយសន្ធិសញ្ញា

បំពេញបន្ថែម ទៅលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ឆ្នាំ១៩៨៥” អនុមតិដោយរដ្ឋសភាខ្មែរ (លើកលែងតែគណបក្ស សម-រង្ស៊ី) និងត្រូវបានទទួលសច្ចានុមតិ ពីព្រះមហាក្សត្រនរោត្តម សីហមុនី ក្រោមការបង្ក្រាបយ៉ាងឃោរឃៅ លើពួកតវ៉ាជាច្រើន និងការគំរាមប្តូររបបរាជាធិបតេយ្យ នៃប្រទេសកម្ពុជា ដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន។

រីឯនៅលើទីកន្លែងផ្ទាល់វិញ ការបោះបង្គោលព្រំដែនថ្មី រវាងកម្ពុជានិងវៀតណាម ដែលបានចាប់ផ្តើម តាំងពីឆ្នាំ១៩៨៦មក បានត្រូវធ្វើឡើង ដោយប្រើលាយឡំផែនទី"បោន" ខ្នាត១/១០០០០០ និងផែនទី"យូធីអឹម" ខ្នាត១/៥០០០០ផង។ ការបោះបង្គោលព្រំដែនថ្មីនេះ បានបណ្តាលឲ្យកើតការតវ៉ាជាច្រើន ពីសំណាក់ប្រជាពលរដ្ឋខ្មែរ នៅតាមគ្រប់ខេត្តខ្មែរ នៅជាប់ព្រំប្រទល់ ជាមួយវៀតណាម ចាប់ពីខេត្តមណ្ឌលគីរី មកដល់ខេត្តកំពត ដោយប្រជាពលរដ្ឋទាំងនោះ បានបញ្ជាក់អះអាងថា បង្គោលព្រំដែនថ្មី បានបោះចូលមកយ៉ាងជ្រៅ មកក្នុងទឹកដីខ្មែរ ចំនួន១គីឡូម៉ែត្រ ២គីឡូម៉ែត្រ ៥គីឡូម៉ែត្រ ឬក៏លើសពី២០គីឡូម៉ែត្រផង ពីព្រំដែនរួម ដែលគេធ្លាប់បានស្គាល់ នាពេលមុន។

នៅក្នុងលក្ខខ័ណ្ឌបែបនេះ និងជាមួយផែនទីកម្ពុជាថ្មី "ដែលផលិត និងផ្តល់ឲ្យ ដោយវៀតណាម" (តាមសេចក្តីថ្លែងការណ៍ផ្ទាល់ របស់លោកវ៉ា គឹមហុង នៃរដ្ឋាភិបាលហ៊ុន សែន នោះ) តើប្រទេសបារាំង ដែលជាអតីតមហាអំណាចអាណានិគម នៃឥណ្ឌូចិន អាចនឹងទទួលជួយ ធ្វើការកែផ្ទេរបច្ចេកទេស លើផែនទី តាមការស្នើរសុំ របស់លោកហ៊ុន សែន និងក្រុងហាណូយនេះ ដែរឬទេ?។

ច្បាប់អន្តរជាតិ ដែលត្រូវបានបញ្ជាក់ ក្នុងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ ឆ្នាំ១៩៩១ ស្តីពីកម្ពុជា និងក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣នោះ បានថ្កោលយ៉ាងជាក់ច្បាស់ ចំពោះការអនុវត្តន៍ផែនទីភូមិសាស្រ្តទាំងឡាយណា ដែលកើតចេញ ពីសន្ធិសញ្ញាដែនដី នៅទសវត្សរ៍១៩៨០ និងរបស់ហៅថា "សន្ធិសញ្ញាបំពេញបន្ថែម លើសន្ធិសញ្ញាឆ្នាំ១៩៨៥" កាលពីឆ្នាំ២០០៥ នោះផង។ នេះគឺ ដើម្បីការរក្សានិងកិច្ចគាំពាររដ្ឋ និងលក្ខន្តិកៈអន្តរជាតិ នៃប្រទេសកម្ពុជា។ ការប្រកែក របស់វៀតណាម មិនព្រមគោរព ចំពោះបូរណភាពដែនដីនៃកម្ពុជា និងផែនទីភូមិសាស្រ្ត ជាប្រវត្តិសាស្រ្តរបស់ខ្លួននេះ វាបានបើកផ្លូវ ឲ្យមានការតវ៉ាទាមទារផ្សេងៗទៀត ចំពោះព្រំដែនកម្ពុជា អំពីប្រទេសជិតខាងមួយទៀត គឺ ប្រទេសថៃឡង់ដ៍ ដែលបានច្បាមយក កាលពីឆ្នាំ១៩៩៧ នូវដែនសមុទ្រខ្មែរ ទំហំប្រហែល៣០ ០០០គីឡូម៉ែត្រក្រឡា ហើយ នៅលើដែនដីគោកវិញ ថៃឡង់ដ៍ក៏បានបញ្ចេញ បំណងរបស់គេ ថានឹងប្រានចោល សន្ធិសញ្ញាបារាំង-សៀម នៃដើមសតវត្សទី២០ ដែលបានកំណត់ ព្រំដែនគោករបស់ខ្លួន ជាមួយកម្ពុជាផងដែរ។

យ៉ាងដូច្នេះ គ្រប់កិច្ចប្រតិបត្តិការបច្ចេកទេស លើផែនទីភូមិសាស្រ្ត នៃប្រទេសកម្ពុជា ពុំត្រូវអនុញ្ញាតឲ្យធ្វើបានទេ និងត្រូវថ្កោលទោសថែមទៀត នៅគ្រាណា ដែលវាជួយ ដោយបែបណាមួយ ទៅដល់ការរំលោភ លើបូរណភាពដែនដីនៃកម្ពុជា ដែលត្រូវបានកំណត់ ដោយសន្ធិសញ្ញា នៃក្រុងហ្សឺណែវ ស្តីពីឥណ្ឌូចិន ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៤ហើយ។

យើងទាំងអស់គ្នា ប្រកាសប្រឆាំងដាច់ខាតទៀត ចំពោះការកែប្រែ ឬការលុបចោល **មាត្រា២** នៃ រដ្ឋធម្មនុញ្ញកម្ពុជា ដែលបានចែងច្បាស់ថា: "**បូរណភាពទឹកដី របស់ព្រះរាជា-ណាចក្រកម្ពុជា ពុំអាចរំលោភបានដាច់ខាត ក្នុងព្រំដែនរបស់ខ្លួន ដែលមានកំណត់ ក្នុងផែនទី ខ្នាត១/១០០០០០ ធ្វើនៅចន្លោះឆ្នាំ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ នៅចន្លោះឆ្នាំ១៩៦៣-១៩៦៩**"។

ទីក្រុងប៉ារីស ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦

គណកម្មាធិការ ព្រំដែន កម្ពុជា ប្រចាំប្រទេសបារាំង



**<u>ស៊ាន ប៉េងសែ</u>**

*ប្រធាន*